**ស្ថានទូតជប៉ុនប្រចាំកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

## ជប៉ុនបញ្ជូនសិស្សស្ម័គ្រចិត្តបង្វឹកកីឡាយូដូដល់កម្ពុជា

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

ក្រសួងការបរទេសជប៉ុននឹងបញ្ជូនសិស្សស្ម័គ្រចិត្ត៨រូប ដើម្បីធ្វើការបង្វឹកកីឡាយូដូ ដែលជាកីឡាយុទ្ធសិល្ប៍ជប៉ុនដ៏ល្បីល្បាញបំផុត ដល់កម្ពុជាចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៥ ក្រោមកម្មវិធី **“កីឡាសម្រាប់ថ្ងៃស្អែក”** ក្រោមកិច្ចសហការជាមួយសហព័ន្ធយូដូជប៉ុនដោយឯកឧត្តម **ហ្គោតារ៉ូ អូហ្គាវ៉ា** ទីប្រឹក្សាសហព័ន្ធយូដូជប៉ុន និងជាអតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាជាអ្នកដឹកនាំក្រុម។

ក្រុមស្ម័គ្រចិត្តនឹងមានគម្រោងបណ្តុះបណ្តាលយុវជន ដែលហ្វឹកហាត់កីឡាយូដូនៅទីក្រុងភ្នំពេញ និងខេត្តសៀមរាបទៅតាមពេលវេលដែលបានជម្រាបជូនខាងលើ។

យើងសង្ឃឹមថាការបញ្ជូនក្រុមស្ម័គ្រចិត្តទាំងនេះ នឹងអាចពង្រឹងនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និងកម្ពុជាក៏ដូចជាអភិវឌ្ឍចលនាការឆ្ពោះទៅកាន់កីឡាអូឡាំពិក និងកីឡាប៉ារ៉ាឡាំពិកតូក្យូ២០២០។

កម្មវិធីបញ្ជូនដោយក្រសួងនេះគឺមានគោលដៅជម្រុញកិច្ចសហប្រតិបត្តិការអន្តរជាតិនិងបម្លាស់ប្តូរនៅក្នុងវិស័យកីឡាក្នុងចំណោមប្រទេសជប៉ុន និងបណ្តាប្រទេសដទៃទៀតតាមរយៈការបញ្ជូនអត្តពលិក និងគ្រូបង្វឹកដែលជាផ្នែកមួយនៃកម្មវិធី **“កីឡាសម្រាប់ថ្ងៃស្អែក”** ដោយរដ្ឋាភិបាលជប៉ុន។

- **កីឡាសម្រាប់ថ្ងៃស្អែក**

*កីឡាសម្រាប់ថ្ងៃស្អែកគឺជាកម្មវិធីដែលផ្តួចផ្តើមឡើងដោយរដ្ឋាភិបាលជប៉ុន ដើម្បីផ្សព្វផ្សាយកីឡាទៅកាន់ប្រជាជនជាង១០លាននាក់ក្នុង១០០ប្រទេស រវាងឆ្នាំ២០១៤ និងឆ្នាំ២០២០ ជាឆ្នាំដែលទីក្រុងតូក្យូនិងធ្វើជាម្ចាស់ផ្ទះកីឡាប៉ារ៉ាឡាំពិក និងកីឡាអូឡាំពិករដូវក្តៅ។ គោលដៅគឺដើម្បីជម្រុញតម្លៃដែលបានហាត់រៀនតាមរយៈកីឡា និងបង្កើនការយល់ដឹងអំពីចលនាកីឡាប៉ារ៉ាឡាំពិកនិងកីឡាអូឡាំពិកទៅកាន់ប្រជាជនគ្រប់ជំនាន់នៅទូទាំងពិភពលោក។*

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162, Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*